ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៥២៣ សណ កសក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យអនុវត្តជំហានដំបូងមុខងារស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រក្នុងទម្រង់អេឡិចត្រូនិកនៃប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជា ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដើម្បីចូលរួមលើកកម្ពស់បន្ថែមទៀតនូវប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំដាក់ឱ្យអនុវត្តជំហានដំបូងដែលមានមុខងារសំខាន់ក្នុងការស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រក្នុងទម្រង់អេឡិចត្រូនិក។

ក្នុងន័យដូចបានជម្រាបជូនខាងលើ និងអនុលោមទៅតាមប្រកាសលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានសម្រេចដាក់ឱ្យអនុវត្តជំហានដំបូងលើមុខងារស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រក្នុងទម្រង់អេឡិចត្រូនិក (https://live.nsw.gov.kh) ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សម្រាប់អង្គភាពទាំង៣ រួមមាន៖

១. **អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ៖** អនុវត្តលើគោលការណ៍ផ្សេងៗក្នុងផ្នែកចំណីសត្វ និងបសុឱសថ។

២. **អគ្គនាយកដ្ឋានកសិកម្ម៖** អនុវត្តលើការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ការនាំចេញទៅវិញ និងវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

៣. **រដ្ឋបាលជលផល៖** អនុវត្តលើការស្នើសុំអាជ្ញាប័ណ្ណនាំចេញ នាំចូល និងឆ្លងកាត់ផល ផលិតផលជលផល។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តតាមការគួរ។

ថ្ងៃ អង្គារ ១៤កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២១

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ព័ត៌មានលម្អិតសូមទំនាក់ទំនង៖**
-លោក សួន សុធឿន (០១២ ៧១៤ ៦៨៤)
-លោក ហាវ ផា (០១២ ៨៣៧ ៥៦៥)